# បឋអប់រំខ្ទី

## ស្តីអំពី: លក្ខណៈពិសេសនៃព្រះពុទ្ធសាសនា

**សំណួរ:** តើព្រះពុទ្ធសាសនាមានលក្ខណៈពិសេសប៉ុន្មានយ៉ាង និងផ្សេងពីពាហិរសាសនាដូចម្តេច?

តាមគោលចារិកនៃលទ្ធិ(doctrine) ឬក៏ប្រពៃណី (tradition)របស់សាសនាឬជាតិសាសន៍នីមួយៗក្នុងលោក តែងតែមានលក្ខណៈពិសេសទៅតាមរចនាសម្ព័ន្ធ បរិបទបញ្ញត្តិរៀងៗខ្លួន ។ លក្ខខណ្ឌពិសេសទាំងនោះទាមទារឲ្យស្ថាបនិកសាសនានីមួយៗ បង្កើតរចនាបទលក្ខន្តិកៈរបស់ខ្លួនយ៉ាងជាក់លាក់ ដើម្បីសម្គាល់នូវអត្តសញ្ញាណនៃលទ្ធិទុកជាទីគោរពប្រតិបត្តិផង ដើម្បីជាសូចនាករបំពេញប្រយោជន៍ និងដឹកនាំសង្គមតាមប្រព័ន្ធសុខដុមរមនូបនីយកម្មផង ។

ព្រោះហេតុនោះ ទើបព្រះពុទ្ធសាសនាបង្កប់នូវលក្ខណៈពិសេស៣យ៉ាង ដែលប្លែកពីលទ្ធិសាសនាដទៃ ។ យើងស្វែងយល់ទាំងអស់គ្នា ដូចខាងក្រោម៖

១. **វិធីសាស្ត្រ** (methodology) បានដល់ការហាត់រៀនធ្វើពិធីផ្សេងៗក្នុងពុទ្ធសាសនា មានពិធីនមស្សការព្រះរតនត្រ័យ ពិធីថ្វាយខ្លួនជាឧបាសកសិកា ពិធីបំបួសកុលបុត្រ ពិធីប្រើប្រាស់បច្ច័យ៤ ពិធីធ្វើទានរក្សាសីលចម្រើនមេត្តាភាវនា និងពិធីបុណ្យផ្សេងៗ មានមាឃបូជាវិសាខបូជាជាដើម ។ បានជាមានវិធីសាស្ត្រដូច្នេះ ដើម្បីអប់រំពុទ្ធសាសនិកឲ្យមានការចាប់អារម្មណ៍ នឹករលឹកចំពោះអភិលក្ខិតកាលក្នុងពុទ្ធសាសនាផង ឲ្យមានរបៀបបែបបទល្អ មានសុជីវធម៌ចំពោះការងារផង ជាកត្តាមួយអាចបំបាត់ទម្លាប់ចាស់ដែលមិនល្អឲ្យបានទទួលនូវទម្លាប់ថ្មីដែលល្អផង ។

២. ***និទស្សន:*** (demonstration) វិចារណកិច្ចជាគ្រឿងបង្ហាញហេតុផលនៃសច្ចៈ បានដល់បុគ្គលាធិដ្ឋានធម៌ និយាយប្រកាសពី អត្ថៈ(ប្រយោជន៍) អនត្ថៈ(អំពើមិនប្រយោជន៍) ផលបុណ្យ បាប នរក សួគ៌ ឲ្យឃើញច្បាស់នូវសកម្មភាពរបស់អ្នកធ្វើអំពើល្អ បានផលល្អ អ្នកធ្វើអំពើអាក្រក់បានផលអាក្រក់ ដូចក្នុងទេវទូតសូត្រ និងក្នុងគម្ពីរធម្មបទ វិមានវត្ថុ បេតវត្ថុជាដើម ។ បានជាមាននិទស្សនៈដូច្នេះ ដើម្បីអប់រំសតិសម្បជញ្ញៈរបស់ពុទ្ធសាសនិក ឲ្យចេះស្រឡាញ់អំពើល្អ និងស្អប់ខ្ពើមអំពើអាក្រក់ផង ឲ្យមានសទ្ធាជឿនូវកម្មផលច្បាស់លាស់តាមសភាវៈពិតផង ។

៣. ***ទស្សនវិជ្ជា*** (philosophy) បានដល់បដិច្ចសមុប្បាទធម៌មានអវិជ្ជា ពោលគឺការមិនចេះមិនដឹងនូវហេតុផលពិតជាដើម និងអរិយសច្ចធម៌មានទុក្ខសច្ច ពោលគឺ សភាវៈធ្វើទុក្ខបុកម្នេញនូវកាយនិងចិត្តមនុស្ស

សត្វឲ្យលំបាកយ៉ាក់យ៉ាប់ជាដើម សម្រាប់ពុទ្ធសាសនិក សិក្សាពិសោធ ឲ្យមានប្រាជ្ញាញាណជាបញ្ញវន្តដឹងស្គាល់ច្បាស់ នូវសភាវៈពិតរបស់លោកធាតុដើម្បីសាងជីវិតឲ្យបានសុខសន្តិភាពនិងបរមសុខជាអមតៈ ។

ចំណែកខាង ពាហិរសាសនាទាំងអស់ក្នុងលោក ដូចព្រហ្មញ្ញសាសនាជាដើម មានតែលក្ខណៈ២យ៉ាង គឺមានតែវិធីសាស្ត្រនិងនិទស្សនៈប៉ុណ្ណោះ មិនមានទស្សនវិជ្ជាផងទេ ឯវិធីសាស្ត្រ និងនិទស្សនៈរបស់ពាហិរសាសនានោះទៀតសោត ក៏មិនដូចខាងពុទ្ធ-សាសនាឡើយ ច្រើនតែខ្វះហេតុផល ។ បើទោះបីពួកគេសន្មតថាមានទស្សនវិជ្ជា ក៏ទស្សនវិជ្ជានោះឆ្លុះ-បញ្ចាំងផ្អែកជាខ្លាំងទៅលើតែព្រះអាទិទេព ពុំអាចជាគន្លឹះយកមកដោះស្រាយ និងបញ្ចប់នូវសេចក្តីទុក្ខក្នុងជីវិតបានឡើយ ៕

(ដកស្រង់សម្រួលពីអត្ថបទ ព្រះសិទ្ធត្ថោ សុង ស៊ីវ ដោយសាមណេរអគ្គសិរីវិមលញ្ញាណ លី ប៊ុន លីង)

# លោកគ្រូព្រះមហាធម្មាលង្ការោ ចាន់ សុជន
# ប្រធានកម្មវិធីធាជីសំឡេងព្រះធម៌
# វត្តប្រាសាទស្រះកណ្តាល(ខ្ពស់)

បានពិនិត្យ

និងឯកភាព

*ធ្វើនៅវត្តប្រាសាទស្រះកណ្តាល(ខ្ពស់)*

*៨កើត ខែជេស្ឋ ព.ស.២៥៥៨*

*ត្រូវនិងថ្ងៃទី ខែមិថុនា ឆ្នាំ២០១៨*